ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
លេខ: ០០៤ សសរ ក.ជ.អ.ប.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការ ក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព

## ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដោយប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រមក/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ/បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញសេចក្តីសម្រេចលេខ ០១៥ សសរ .ប.ស្ត ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងបរិស្ថានស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិសម្របសម្រួលកិច្ចសហប្រតិបត្តិការកម្ពុជា-រុស្ស៊ី ក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព
- យោងតាមស្មារតីអង្គប្រជុំលើកទី២ របស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧
- យោងតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។



អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមការងារថ្នាក់ជាតិដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រើប្រាស់ថាមពលនិងបច្ចេកវិទ្យានុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ. បណ្ឌិត **ទិន ពន្លក** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) | ប្រធាន |
| ២. ឯ.ឧ. **សុខ គាន** | ទីប្រឹក្សាអមក្រសួងបរិស្ថាន | អនុប្រធាន |
| ៣. ឯ.ឧ. បណ្ឌិត **តាច សុខុន្ធី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | អនុប្រធាន |
| ៤. លោក **ជា ចន្ទន៍ធូ** | ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | សមាជិក |
| ៥. លោក **តាំង ម៉េងអៀង** | ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | សមាជិក |
| ៦. លោក **ផិត ពេជរ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ៧. លោក **ជៀប ប៊ុនអៀង** | ប្រធាននាយកដ្ឋានអប់រំបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ៨. ឯ.ឧ.បណ្ឌិត **នុត សម្បត្តិ** | ប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម រាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ៩. លោក **ញ៉ៀម សូលីវ៉ាន់** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងការអភិវឌ្ឍធនធានមនុស្សក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | សមាជិក |
| ១០. លោក **ម៉ែន គៀហាក់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១១. លោក **ចាន់ សុជាវ៉ាត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១២.លោក **ឈាង វណ្ណារិទ្ធ** | ប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. លោក វេជ្ជ. **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល | សមាជិក |

| | | |
|---|---|---|
| ១៤ លោក **សំអោ អង្គារតេន៍** | ប្រធាននាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥. លោក **អំ តិរម្យ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦. បណ្ឌិត **អ៊ុម រម្យណី** | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ១៧. បណ្ឌិត **ធន់ វឌ្ឍនា** | នាយកសាលាជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៨. លោក **សេង ជ័យឧត្តម** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃសាកលវិទ្យាល័យបាត់ដំបង | សមាជិក |
| ១៩. លោក **ឡោ លីត្ត** | ព្រឹទ្ធបុរសរងទទួលបន្ទុករួមមហាវិទ្យាល័យវិស្វកម្មកសិកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ២០. បណ្ឌិត **ជ័យ ចាន់អឿន** | អ្នកសម្របសម្រួលកម្មវិធីបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែករូបវិទ្យា មហាវិទ្យាល័យវិទ្យាសាស្ត្រសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក។ |

**ប្រការ២..**

ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ផ្ដល់យោបល់ជូនរាជរដ្ឋាភិបាល តាមរយៈយន្តការ ក.ជ.អ.ថ. ដើម្បីពិនិត្យ និងអនុម័ត លើសេចក្ដីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធី និងគម្រោងនានា ពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ដែលគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព
- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ កំណត់ទិសដៅការងារអាទិភាព និងកៀរគរធនធាន ដើម្បីអនុវត្តកិច្ចព្រមព្រៀង និងគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព
- រៀបចំផែនការស្រាវជ្រាវ និងកសាងសមត្ថភាពមន្ត្រីជំនាញ អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស ដល់គ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ តាមរយៈការសិក្សា ស្រាវជ្រាវ វគ្គបណ្ដុះបណ្ដាល ទស្សនកិច្ចសិក្សា វេទិកា និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការអប់រំនិងផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព តាមរយៈមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពនានាពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពលនុយក្លេអ៊ែររបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់

- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារសហប្រតិបត្តិការជាមួយភាគីទាំងអស់ ជូនប្រធាន ក.ជ.អ.ច. និងក្នុងករណីចាំបាច់ ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច
- អនុវត្តភារកិច្ចនានា តាមការប្រគល់ជូនរបស់ប្រធាន ក.ជ.អ.ច.។

**ប្រការ៣..**

ក្រុមការងារនេះមានលេខាធិការដ្ឋានជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក **ជា ចន្ទន៍ធូ** | ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | ប្រធាន |
| ២. លោក **ឌិត ពេធរ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន | អនុប្រធាន |
| ៣. លោក **តាំង ម៉េងអៀង** | ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | អនុប្រធាន |
| ៤. បណ្ឌិត **ហាក់ ម៉ៅ** | អនុប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | សមាជិក |
| ៥. លោក **សុខ សីលា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | សមាជិក។ |

លេខាធិការដ្ឋានមានភារកិច្ចចាត់ចែងការងាររដ្ឋបាល រៀបចំឯកសារសម្រាប់កិច្ចប្រជុំ ធ្វើរបាយការណ៍ជូនប្រធានក្រុមការងារ និងទទួលអនុវត្តភារកិច្ចនានាតាមការប្រគល់ជូនរបស់ប្រធាន។ លេខាធិការដ្ឋាននេះមានទីតាំងនៅនាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.។

**ប្រការ៤..**

ក្រុមការងារថ្នាក់ជាតិត្រូវប្រជុំឱ្យបានទៀងទាត់ជារៀងរាល់ ៣ (បី) ខែម្តង។ ក្នុងករណីចាំបាច់ ក្រុមការងារអាចរៀបចំកិច្ចប្រជុំតាមការសម្រេចរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវដឹកនាំកិច្ចប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ៥..**

ក្រុមការងារមានសិទ្ធិអញ្ជើញអ្នកស្រាវជ្រាវ ទីប្រឹក្សាបច្ចេកទេស អ្នកបច្ចេកទេស អ្នកជំនាញ និងអ្នកពាក់ព័ន្ធនានា ចូលរួមផ្តល់យោបល់នៅក្នុងកិចប្រជុំបច្ចេកទេស ពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព តាមការចាំបាច់។

**ប្រការ៦..**

សេចក្តីសម្រេចលេខ០១៥ សសរ .ប.ស្ត ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងបរិស្ថាន ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិសម្របសម្រួលកិច្ចសហប្រតិបត្តិការកម្ពុជា-រុស្ស៊ី ក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧..**

ក្រសួង ស្ថាប័ន គណៈអភិបាលរាជធានី ខេត្ត ជាសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕/ស/ល

ថ្ងៃ សុក្រ ៣ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧«ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ